ការបោះពុម្ពផ្សាយលើកទី១ក្នុងឆ្នាំ ២០២៤

GADC
អង្គការយេនឌ័រ និងអភិវឌ្ឍន៍ ដើម្បីកម្ពុជា
Gender and Development for Cambodia

# ការពិភាក្សា & ទស្សនៈបុរស



## នៅក្នុងខេត្តកំពង់ឆ្នាំង

ក្រុមការងារបណ្តាញបុរសកម្ពុជា (CMN) បានជួបជុំជាក្រុមតូចនិងមានរយៈពេលខ្លី ជាមួយបងប្អូនដែលជាបុរសមកពីសហគមន៍ ដើម្បីស្វែងយល់ពីការពិភាក្សាអំពីទស្សនៈបុរស **លើប្រធានបទនៃ**

## ការរំលូត ហើយប្រសិនបើការរំលូតត្រូវបានគេមើលឃើញថា គួរតែត្រូវបានពិភាក្សាដោយបើកចំហពីភាពអវិជ្ជមាន ឬ វិជ្ជមានរបស់វា។

**នៅក្នុងការពិភាក្សាដ៏ខ្លីនេះ** បុរសមួយក្រុមតូចបានចែករំលែកគំនិតទស្សនៈ និងការយល់ដឹងអំពីការរំលូតក្នុងសហគមន៍របស់ពួកគេ និងនៅក្នុងសង្គមជាតិទាំងមូល។

**ទស្សនៈរបស់ពួកគេដំបូងឡើយយល់ឃើញថា** ការរំលូតមិនល្អទេ មនុស្សគួរតែខិតខំបង្កើតកូន និងប្រសិនបើអាចធ្វើទៅបាន ស្ត្រីគួរតែផ្តោតលើការចិញ្ចឹមបីបាច់ថែរក្សាកូន ជាជាងការយកចេញ។



**ជាងនេះទៅទៀត** ពួកគេបានលើកឡើងពីហានិភ័យក្នុងការរំលូតជាពិសេសនៅតាមតំបន់ជនបទដោយសារតែខ្វះធនធានផ្នែកវេជ្ជសាស្ត្រក្នុងការរំលូត ដូច្នេះហើយដើម្បីឱ្យមានសុវត្ថិភាពស្ត្រីគួរតែរក្សាការពរពោះនោះ។



### អ្នកចូលរួមជាបុរសមួយចំនួន

ទោះបីជាក្នុងករណីមានការរំលោភផ្លូវភេទក៏ដោយ ការរំលូតគឺនៅតែជាវិធីដែលគ្រោះថ្នាក់ខ្លាំងដែលមិនគួរធ្វើ

ដូច្នេះស្ត្រីគួរតែរក្សាការមានផ្ទៃពោះនោះ។ ប៉ុន្តែបន្ទាប់ពីមានការពិភាក្សា និងសួរសំណួរគ្នាបន្តទៀត ទស្សនៈរបស់ពួកគេចាប់ផ្តើមផ្លាស់ប្តូរ និងយល់ស្របលើចំណុចរួមមួយ ដោយពួកគេបានចែករំលែកគំនិត ជាតុចូលដល់ដោយផ្តល់ចម្លើយ និងការយល់ឃើញទៅតាមបរិបទ និងកាលៈទេសៈជុំវិញការរំលូត។

# អ្នកចូលរួម ចាប់ផ្តើមចែករំលែកកាន់តែច្រើន

ប៉ុន្តែទស្សនៈរបស់ពួកគេបានផ្លាស់ប្តូរពីអ្វីដែលពួកគេបានចែករំលែកនៅពេលចាប់ផ្តើម ដែលដំបូងគំនិតទាំងនោះហាក់មិនមែនជាជំនឿរបស់ពួកគេឡើយ។ ហើយពេលពួកគេបានចម្លើយបន្ថែមនៅក្នុងដៃការពិភាក្សា និងការវិភាគកាន់តែស៊ីជម្រៅ ធ្វើឲ្យពួកគេមានការចាប់អារម្មណ៍ចូលរួមកាន់តែច្រើនលើប្រធានបទនេះ ព្រមទាំងបង្ហាញពីឆន្ទៈក្នុងការស្វែងយល់លើទិដ្ឋភាពផ្សេងៗទៀតដែលអាចមានឥទ្ធិពលលើបញ្ហានេះ។

**ពេលធ្វើការពិភាក្សាបន្តទៀត** បុរសៗបានសម្តែងមតិរួមថា ការរំលូតគឺជាការចាំបាច់សម្រាប់លក្ខខណ្ឌខ្លះ ប្រសិនបើវាធ្វើឱ្យគ្រោះថ្នាក់ដល់សុខភាពម្តាយ ឬត្រូវបានណែនាំដោយវេជ្ជបណ្ឌិត នៅចំណុចនេះគឺ ស្ត្រីគួរតែពិចារណាជម្រើសទាំងនោះ។ កិច្ចពិភាក្សាបានបន្ត ដោយអ្នកចូលរួមបានគូសបញ្ជាក់ផងដែរថា ការរំលូតគួរតែត្រូវបានអនុញ្ញាត ប្រសិនបើអ្នកមានផ្ទៃពោះមិនចង់បាន នោះជម្រើសគួរតែស្ថិតនៅលើអ្នកពរពោះកូន ប៉ុន្តែសម្រាប់អ្នកចូលរួមមួយចំនួនទៀតដែលមានគ្រួសារ និងមានកូន បាននិយាយថា ការជជែកពិភាក្សាពីការរំលូតរបស់ភរិយាគួរធ្វើពិចារណាឡើងវិញជាមុន ដើម្បីភាពច្បាស់លាស់ និងស្រាយមន្ទិលសង្ស័យផ្សេងៗ និងបញ្ចុះបញ្ចូលប្រពន្ធនូវជម្រើសផ្សេងវិញ។




ត្រង់ចំណុចនេះ អ្នកចូលរួមមួយចំនួនក្នុងក្រុមបានបង្ហាញការមិនយល់ស្របថា ការរំលូតគួរតែជាជម្រើសរបស់ភរិយាដែលមានផ្ទៃពោះ ហើយសមាជិកគ្រួសារត្រូវគាំទ្រការសម្រេចចិត្តរបស់ភរិយាមិនចាំបាច់សុំយោបល់ពីមានសមាជិកគ្រួសារផ្សេងទៀតទេ។

“ប្រធានបទនៃការរំលូតគឺមានភាពស្មុគស្មាញ ការមានកូនគឺជាការសម្រេចចិត្តដ៏ធំមួយ ហើយដូចគ្នាទៅនឹងការរំលូតដែរ ប្រសិនបើការមានផ្ទៃពោះមានគ្រោះថ្នាក់ដល់ជីវិត ការរំលូតគួរតែជាជម្រើស ហើយគួរពិភាក្សាជាមួយគ្រូពេទ្យ ប៉ុន្តែប្រសិនបើការមានផ្ទៃពោះមិនមានផលប៉ះពាល់អវិជ្ជមានណាមួយទេ ហើយអ្នកដែលមានផ្ទៃពោះនៅតែចង់ធ្វើការរំលូត សមាជិកគ្រួសារត្រូវតែធ្វើការពិភាក្សា និងពិចារណារួមគ្នា (គ្រួសារទាំងមូលរួមមានឪពុកម្តាយក្មេក) ទស្សនៈរួមរបស់អ្នកចូលរួមជាបុរស

**ទិដ្ឋភាពមួយទៀតដែលត្រូវបាននិយាយអំពីការរំលូត** គឺគោលជំហររបស់សាសនា ដើម្បីមើលថា តើសាសនាមានឥទ្ធិពលដល់ការរំលូត ហើយថាតើសាសនាបានកំណត់ទស្សនៈរបស់ពួកគេលើការរំលូតបែបណា។ អ្នកចូលរួមទាំងអស់បានយល់ស្របដូចគ្នាថា ការសម្លាប់ និងការរំលូតគឺជាអំពើបាប ប៉ុន្តែអ្នកចូលរួមម្នាក់បាននិយាយថា៖



“កម្ម និងបាបមិនគួរជាកត្តាចំបងទេ (បើការរំលូត គឺទាក់ទងនឹងសុខភាព) មានកត្តាផ្សេងៗទៀតដែលសំខាន់ជាងនេះ ដូចជាក្នុងការពិចារណាលើហានិភ័យដល់អាយុមាតា ស្ថិរភាពសេដ្ឋកិច្ចក្នុងសង្គម ការផ្គត់ផ្គង់ចិញ្ចឹមបីបាច់កូនក្នុងបន្ទុកគ្រួសារជាដើម ...

## ប្រធានបទទី២

ដែលត្រូវបានយកមកពិភាក្សាគឺផលិតផលសំឡីអនាម័យ។ ការពិភាក្សាបានចាប់ផ្ដើមដោយសំណួរសាមញ្ញមួយគឺ តើផលិតផលសំឡីអនាម័យគួរតែមានផ្ទុកសម្រាប់អ្នកមានតម្រូវការ និងអាចមាននៅគ្រប់ទីកន្លែង ជាពិសេសកន្លែងសាធារណៈ ដូចជា បន្ទប់ទឹកសាធារណៈ បន្ទប់ទឹកសាលារៀន បន្ទប់ទឹកកន្លែងធ្វើការ។

**អ្នកចូលរួមទាំងអស់**បានដឹងហើយថា បច្ចុប្បន្ននេះ សំឡីអនាម័យមានដាក់លក់ជាសាធារណៈច្រើនសម្រាប់អ្នកដែលត្រូវការវា។



**អ្នកចូលរួមទាំងអស់បាន** ចែករំលែកថា ផលិតផលទាំងនេះមានសារៈសំខាន់ណាស់ ដោយសារវាទាក់ទងទៅនឹងសុខភាព និងសុខុមាលភាពរបស់បងប្អូនជាស្ត្រី ហើយផលិតផលទាំងនេះគួរតែត្រូវបានដាក់នៅគ្រប់ទីកន្លែងដើម្បីបង្កភាពងាយស្រួលក្នុងការប្រើប្រាស់។ បុរសៗបានលើកឡើងពីមូលហេតុដែលពួកគេជឿ និងបានចែករំលែកគំនិតរបស់ពួកគេថា



“ទាក់ទងនឹងរឿងរ៉ាវសំឡីអនាម័យនេះ គឺជារឿងធម្មតាទៅហើយសម្រាប់ខ្ញុំ ព្រោះវាជារឿងធម្មជាតិ ហើយសុខភាពរបស់បងប្អូនស្ត្រីគួរតែជាទិដ្ឋភាពសំខាន់ដែលគួរយកចិត្តទុកដាក់ ជំនួសឱ្យការអាម៉ាស់ និងការហាមឃាត់” ការយល់ឃើញរបស់អ្នកចូលរួម

**បន្ទាប់មកការពិភាក្សា**ត្រូវបានផ្លាស់ប្ដូររបៀបក្នុងការជជែក ដោយចាប់ផ្ដើមមើលទៅលើភាពអាម៉ាស់ ការហាមឃាត់ និងការសម្ងាត់ជុំវិញផលិតផលសំឡីអនាម័យ។ ទស្សនៈបុរសខ្លះនៅក្នុងក្រុមយល់ថាសំឡីអនាម័យធ្វើឲ្យពួកគាត់មិនមានផាសុខភាព ឬមានការខ្មើមអើមជាដើម។





“បុរសខ្លះខ្មាស់អៀន ឬយល់ថាវាគួរឱ្យខ្ពើម ឬជារឿងដែលគួរទុកជារឿងឯកជន ព្រោះសំឡីអនាម័យមិនសូវត្រូវបានគេលើកមកនិយាយ ហើយពួកគេក៏មិនសូវបានដឹងពីការប្រើប្រាស់ផលិតផលទាំងនេះទៀត ទើបធ្វើឲ្យពួកគេមិនយល់ពីសំឡីអនាម័យ។ ផ្ទុយទៅវិញពួកគេបែរជាខ្មាស់អៀន ឬមិនខ្វល់ពីប្រធានបទទាំងនេះ ពីព្រោះរឿងនេះមិនត្រូវបានចែករំលែក ឬបង្រៀនដោយបើកចំហឡើយ ដែលអាចជាមូលហេតុដែលធ្វើឲ្យបុរសមិនយល់។

ទស្សនៈពីអ្នកចូលរួមដែលជាបុរស

# អ្នកចូលរួមទាំងអស់មានគំនិតដូចគ្នាថា

ផលិតផលសំឡីអនាម័យ**គួរតែមាននៅគ្រប់ទីកន្លែង** មិនគួរខ្មាស់អៀន ឬមើលងាយនោះទេ។ អ្នកចូលរួមទាំងអស់បានចែករំលែកថា គួរតែមានលំហ ឬកន្លែងទំនេរ ដើម្បីមានការពិភាក្សាបើកចំហជុំវិញប្រធានបទទាំងនេះ

ដូចជា គួរតែមានមេរៀនអំពីរឿងនេះផងដែរ (ជីវវិទ្យា និងពេលពេញវ័យ) សម្រាប់មនុស្សគ្រប់គ្នា **ព្រោះវាមានសារៈសំខាន់ណាស់**

ក្នុងការយល់ថានេះជារឿងធម្មជាតិ ហើយវាកើតឡើងចំពោះមនុស្សស្រីគ្រប់គ្នា គ្រប់ទីកន្លែង ដូច្នេះវាមិនគួរជារឿងដែលត្រូវខ្មាស់អៀន ឬត្រូវលាក់បាំងនោះទេ ប៉ុន្តែគឺជាការអប់រំ និងបង្កើតបរិយាកាសដើម្បីពិភាក្សា ដែលអាចជួយផ្លាស់ប្តូរទស្សនៈរបស់មនុស្សឲ្យយល់ពីអត្ថន័យនៃការមករដូវ និងមូលហេតុនៃការប្រើប្រាស់សំឡីអនាម័យរបស់ស្ត្រី។





**ដោយ៖**
លោក គីម កែវប្រកប - មន្ត្រី បណ្តាញបុរសកម្ពុជា
លោកស្រី អេង ចាន់ឌី - នាយិកាប្រតិបត្តិ

## Follow us on:

**Gender and Development for Cambodia**

**www.gadc.org.kh**

ផ្ទះលេខ ៣៩B ផ្លូវ៦០៨ សង្កាត់បឹងកក់២ ខណ្ឌទួលគោក ភ្នំពេញ

(+៨៥៥) ០៩៦ ៣២៥ ១៦៩០

CMN
បណ្តាញបុរសកម្ពុជា